**សូមក្រាបបង្គំទូលថ្វាយ**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

បពិត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូងជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ជាបឋម ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាត ថ្លែងនូវអំណរព្រះមហាករុណាទិគុណជាអនេកកប្បការ ថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទាន ព្រះរាជក្រឹត្យចាត់តាំងទូលព្រះបង្គំជាខ្ញុំ ជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

តបនឹងព្រះរាជក្រឹត្យដ៏ខ្ពង់ខ្ពស់បំផុត របស់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទូលព្រះបង្គំជាខ្ញុំ នឹងរៀបចំសមាសភាពរាជរដ្ឋាភិបាល បញ្ជូនទៅព្រឹទ្ធសមាជិក នៃរដ្ឋសភា នីតិកាលទី ៦ ដើម្បីសុំការផ្តល់សេចក្តីទុកចិត្ត ពីសមាជិកសមាជិកានៃរដ្ឋសភា ដែលនឹងប្រជុំនៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ខាងមុខនេះ។

ទូលព្រះបង្គំជាខ្ញុំនឹងខិតខំយកអស់ពីកម្លាំងកាយចិត្ត និងស្មារតី ដើម្បីបំពេញភារកិច្ចដ៏វិសេសវិសាល និងឧត្តុង្គឧត្តម ដែលព្រះករុណាជាអម្ចាស់ទ្រង់បានព្រះរាជទានដល់ទូលព្រះបង្គំជាខ្ញុំ ក្នុងកិច្ចការបំរើប្រទេសជាតិមាតុភូមិ និងប្រជារាស្ត្រទូទាំងប្រទេស ឲ្យបានសមទៅតាមព្រះរាជហឫទ័យទុកដាក់ជាខ្លាំងរបស់ព្រះអង្គ ចំពោះកូនចៅ ចៅទួតរបស់ព្រះអង្គជារៀងដរាបមក។

ជាថ្មីម្តងទៀត ទូលព្រះបង្គំជាខ្ញុំ សូមទូលថ្វាយព្រះពរព្រះករុណាថ្លៃវិសេស ជាទីគោរពសក្ការៈ សូមព្រះអង្គទ្រង់ប្រកបដោយព្រះសុខភាពមាំមួន ព្រះកាយពលសិរីល្អ ព្រះបញ្ញាញាណភ្លឺថ្លា ឈ្លាសវៃ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ចាកផុតពីព្រះរោគាព្យាធិនានា ដើម្បីព្រះអង្គទ្រង់គង់ប្រថាប់ជាម្លប់ យ៉ាងត្រជាក់ត្រជុំ សុខដុមរមនារបស់មាតុភូមិកម្ពុជា ជារៀងរហូតតទៅ។

សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈ ទ្រង់ព្រះមេត្តាទទួលនូវគារវភក្តីដ៏ស្មោះ និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត ពីទូលព្រះបង្គំជាខ្ញុំដោយព្រះរាជហឫទ័យករុណានុគ្រោះ ។

*ថ្ងៃ សុក្រ ៦ កើត ខែ ស្រាពណ៍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២*

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**